រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

# សៀវភៅណែនាំ

# ស្តីពី

# ការរៀបចំគំរោងអភិវឌ្ឍន៍ឃុំ សង្កាត់

បោះពុម្ពដោយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន

គាំទ្រថវិការដោយ UNDP/DSP

ខែ វិច្ឆិកា ឆ្នាំ ២០០២

# មាតិការ

បណ្ណាល័យ
គ.ជ.អ.ប

ទំព័រ

១. អារម្ភកថា ៣
២. គោលបំណង និងលទ្ធផលនៃវគ្គបណ្តុះបណ្តាល ៥
៣. ផ្នែកទី ១: មូលដ្ឋាននៃការរៀបចំគំរោងអភិវឌ្ឍន៍ឃុំ សង្កាត់ ៧
១.១ និយមន័យនៃគំរោង ៧
១.២ គំរោងដែលអាចទទួលបានមូលនិធិឃុំ សង្កាត់ ផ្នែកអភិវឌ្ឍន៍ ៩
១.៣ និយមន័យនៃគំរោងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ១២
១.៤ លក្ខខណ្ឌក្នុងការប្រើប្រាស់មូលនិធិឃុំ សង្កាត់ ផ្នែករភិវឌ្ឍន៍ ១៣
១.៥ សកម្មភាពនានាក្នុងការរៀបចំគំរោង ១៤
១.៦ ពេលវេលានៃការរៀបចំគំរោង ១៥
៤. ផ្នែកទី ២: តួនាទី និងភារកិច្ច របស់អ្នកពាក់ព័ន្ធ ១៦
២.១ ក្រុមប្រឹក្សាឃុំ សង្កាត់ ១៦
២.២ គណៈកម្មាធិការកសាងផែនការ និងថវិកា ១៧
២.៣ មេឃុំ ចៅសង្កាត់ ១៧
២.៤ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ និងស្ថាប័នសង្គមស៊ីវិល ១៨
២.៥ សហគមន៍ និងអ្នកទទួលផលពីគំរោង ១៩
២.៦ ផ្នែករដ្ឋបាលមូលដ្ឋាន ១៩
២.៧ ផ្នែកបច្ចេកទេស ១៩
២.៨ អង្គភាពរដ្ឋបាលមូលដ្ឋាន ២០
២.៩ មន្ទីរជំនាញពាក់ព័ន្ធនានា ២១
២.១០ គណៈកម្មាធិការប្រតិបត្តិ ២៣
៥. ផ្នែកទី ៣: ទំរង់បែបបទ ក្នុងការរៀបចំគំរោង ២៤
៣.១ ពត៌មានពីផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ២៤
៣.២ ផែនទីគំរោង ២៤
៣.៣ ប្លង់ការដ្ឋាន ២៤
៣.៤ ពត៌មានបច្ចេកទេស ២៤
៣.៥ ធនធាននៅមូលដ្ឋាន ២៥

library.ncdd.gov.kh
002976

| | | |
|---|---|---|
| | ៣.៦ ទីកន្លែងវប្បធម៌ និងបរិស្ថាន | ២៥ |
| | ៣.៧ ការប្រើប្រាស់ដីធ្លីសំរាប់គំរោង | ២៦ |
| | ៣.៨ ពត៌មានលំអិតនៃលទ្ធផលគំរោង និងការប៉ាន់ស្មានតំលៃ | ២៧ |
| | ៣.៩ ប្រតិបត្តិការ និងការថែទាំ | ២៧ |
| ៦. | ផ្នែកទី ៤: របៀបបំពេញទំរង់បែបបទពត៌មានគំរោង | ២៩ |
| | ៤.១ ការបំពេញទំរង់បែបបទពត៌មានគំរោង | ២៩ |
| | ៤.២ ពត៌មានដែលត្រូវបំពេញក្នុងទំរង់បែបបទ | ៣០ |
| ៧. | ផ្នែកទី ៥: ដំណើរការពិនិត្យទំរង់បែបបទពត៌មានគំរោង | ៣៨ |
| | ៥.១ ការពិនិត្យដោយអង្គភាពរដ្ឋបាលមូលដ្ឋាន | ៣៨ |
| | ៥.២ ការពិនិត្យ បញ្ជាក់បច្ចេកទេស | ៣៩ |
| ៨. | ផ្នែកទី ៦: ជំហានបន្ទាប់ | ៤០ |
| ៩. | លំហាត់ស្តីពីការរៀបចំថវិកាអភិវឌ្ឍន៍ឃុំ សង្កាត់ | ៤១ |
| ១០. | ឧបសម្ព័ន | |
| | ទំរង់បែបបទផ្សេងៗ | ៤៣ |

# អារម្ភកថា

នៅចុងខែមិនា ឆ្នាំ ២០០២ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ប្រមាណជាង ១១ ០០០ នាក់ និង ស្មៀនឃុំ សង្កាត់ប្រមាណ ១៦២១ នាក់ បានចូលកាន់តំណែងរបស់ខ្លួន ។ ដើម្បីអោយពួកគេអាចអនុវត្តការងារ និងភារកិច្ចរបស់ខ្លួនបានល្អប្រសើរប្រកបដោយប្រសិទ្ធិភាពខ្ពស់នោះ ការកសាងសមត្ថភាព គឺជាលក្ខខ័ណ្ឌទីមួយដែលត្រូវធ្វើដើម្បីសំរេចបាននូវទិសដៅដែលបានលើកឡើងក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តន៍គោលនយោបាយវិមជ្ឈការ បានផ្តោតយ៉ាងខ្លាំង លើការពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ ។ គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ (NCSC) ជាអ្នក ទទួលខុសត្រូវទូទៅ ក្នុងការបង្កើត និងអនុវត្តផែនការពង្រឹងសមត្ថភាពនេះ ។

ឯកសារមេរៀនបណ្តុះបណ្តាល ដែលមានក្នុងដៃរបស់លោកអ្នក គឺជាឯកសារទី៤ហើយ ដែលត្រូវបាន បង្កើតឡើង សំរាប់វគ្គបណ្តុះបណ្តាលដល់ក្រុមប្រឹក្សា និងស្មៀនឃុំ សង្កាត់ ។ ឯកសារមេរៀននេះ នឹងផ្តល់អោយលោកអ្នកនូវ :

- ការយល់ដឹងពីនីតិវិធីសំរាប់ការរៀបចំគំរោង ។
- ការអនុវត្តន៍ជាក់ស្តែងលើការបំពេញទំរង់បែបបទព័តមានគំរោង និងឯកសារចាំបាច់បន្ថែមផ្សេងៗទៀត ។
- ការយល់ដឹង អំពីលក្ខខ័ណ្ឌនៃការប្រើប្រាស់ និងការបែងចែកមូលនិធិឃុំ សង្កាត់ (ចំណាយចរន្ត ចំណាយមូលធនផ្នែកអភិវឌ្ឍន៍ និង ចំណាយផ្នែករដ្ឋបាល)។
- ផែនការសកម្មភាពសំរាប់ការរៀបគំរោង: ឃុំ សង្កាត់អាចបង្កើតបានផែនការសកម្មភាពសំរាប់រៀបចំ និងអនុវត្តគំរោងដែលពួកគេត្រូវអនុវត្ត ។
- ការយល់ដឹងកាន់តែច្បាស់ពីតួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធនឹងដំណើរការរៀបចំ និងការអនុវត្តន៍គំរោង ។
- ការយល់ដឹងពីព័តមានបច្ចេកទេសមួយចំនួនដែលត្រូវប្រមូល និងត្រូវប្រើប្រាស់ដោយអ្នកគាំទ្របច្ចេកទេសរបស់មន្ទីរជំនាញពាក់ព័ន្ធ។

ការបណ្តុះបណ្តាល គឺផ្អែកទៅលើឯកសារមេរៀននេះ ហើយមេរៀននេះ គឺជាផ្នែកទីមួយនៃឯកសារមេរៀនស្តីពីការអនុវត្តន៍គំរោងអភិវឌ្ឍន៍ឃុំ សង្កាត់ ។

ការកសាងសមត្ថភាពគឺជាដំណើរការមួយដែលត្រូវធ្វើឡើងជាប្រចាំ ហើយឯកសារនេះ ក៏ដូចជាមេរៀនទាំងបីមុនដែរ ចាំបាច់ត្រូវធ្វើការពិនិត្យ និងធ្វើកែសំរួលឡើងវិញជាប្រចាំ ដើម្បីធ្វើអោយការពង្រឹងសមត្ថភាពនេះកាន់តែមានប្រសិទ្ធិភាពខ្ពស់ ។ ហេតុដូច្នេះហើយ NCSC នឹងមានអំណរសាទរជានិច្ចចំពោះការផ្តល់យោបល់ដើម្បីកែលំអរពីគ្រូឧទ្ទេសទាំងឡាយ ដែលបានប្រើប្រាស់ឯកសារមេរៀនបណ្តុះបណ្តាលនេះ ។

ភ្នំពេញ, ខែវិច្ឆិកា ឆ្នាំ ២០០២

# ទិសដៅ និងលទ្ធផល នៃវគ្គបណ្តុះបណ្តាល

\+ + + + + + + + + + +

បំណងដើងនៃវគ្គបណ្តុះបណ្តាលនេះ គឺវគ្គបណ្តុះបណ្តាលនៃមេរៀនពីការរៀបចំ និងអនុវត្តគំរោងឃុំ សង្កាត់ ផ្នែកទី ១ ស្តីពី "ការរៀបចំគំរោង" ។ វគ្គបណ្តុះបណ្តាលនេះ គឺជាវគ្គទី៤ហើយដែលបានរៀបចំឡើង សំរាប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងប្រទេស ។ វគ្គបណ្តុះបណ្តាលនៃមេរៀនពីការរៀបចំ និងអនុវត្តគំរោងឃុំ សង្កាត់ ផ្នែកទី២ ស្តីពី "ការអនុវត្តន៍គំរោង" នឹងត្រូវរៀបចំឡើងនាពាក់កណ្តាលខែមករា ឆ្នាំ២០០៣ខាងមុខនេះ ផ្តោតជាសំខាន់លើ "<u>*ការដេញថ្លៃ និងការគ្រប់គ្រងកិច្ចសន្យា*</u>" ។

រហូតមកដល់ពេលនេះ ឃុំ សង្កាត់ បានបញ្ចប់ (ឬស្ទើរតែបញ្ចប់ ) នូវដំណើរការកសាងផែនការមូលដ្ឋាន ការវិភាជន៍ថវិកា ឆ្នាំ ២០០៣ សំរាប់ផ្នែកអភិវឌ្ឍន៍ត្រូវបានធ្វើឡើង ហើយទន្ទឹមនឹងនេះ សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកក៏ទើបតែបានបញ្ចប់ ។ ដូចនេះ ឃុំ សង្កាត់ ចាំបាច់ត្រូវចាប់ផ្តើមរៀបចំ និងអនុវត្តគំរោងអាទិភាពទាំងឡាយដែលមានក្នុងផែនការអភិវឌ្ឍន៍របស់ខ្លួន ។ តាមរយៈវគ្គបណ្តុះបណ្តាលនេះ គោលការណ៍ណែនាំ និងលិខិតបទដ្ឋានទាំងឡាយសំរាប់ការរៀបចំគំរោង នឹងត្រូវបានលើកឡើង និងពន្យល់ដោយប្រើឧទាហរណ៍គំរូមួយចំនួន និងលំហាត់ដែលមានការទាក់ទងទៅនឹងការអនុវត្តន៍ជាក់ស្តែង ព្រមទាំងអោយអ្នកចូលរួមទាំងអស់ សាកល្បងបំពេញបែបបទ ដែលមានក្នុងឯកសារមេរៀននេះ ។

មេរៀនដែលរៀបចំសំរាប់វគ្គបណ្តុះបណ្តាលនេះ គឺផ្តោតលើពត៌មានសំខាន់ៗតែប៉ុណ្ណោះ ហើយវាមានលក្ខណៈងាយយល់សំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ។ វគ្គនីមួយៗ មានប្លង់មេរៀនលំអិតសំរាប់គ្រូឧទ្ទេស និងឯកសារចែកជូនដល់ក្រុមប្រឹក្សា ព្រមទាំងលំហាត់គំរូ សំនួរចំលើយ និងការពិភាក្សាជាច្រើនផងដែរ ។ វគ្គបណ្តុះបណ្តាលនេះ មានរយៈពេល២ថ្ងៃតែប៉ុណ្ណោះ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ ក្រោយពីបញ្ចប់វគ្គនេះហើយ នឹងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរៀបចំគំរោងជាក់ស្តែងរបស់ខ្លួន ។

ឯកសារនេះ ក្រោយពីបានយកទៅសាកល្បងជាមួយឃុំមួយចំនួន គឺត្រូវបានចងក្រង បញ្ចប់សំរាប់វគ្គបណ្តុះបណ្តាលស្តីពីការរៀបចំគំរោងនេះ ។ ទោះបី មានមេរៀនជាច្រើនដែលត្រូវលើកឡើងក្នុងកម្មវិធីបណ្តុះបណ្តាលនេះក្តី ប្រសិនបើគ្រូឧទ្ទេសអនុវត្តតាមប្លង់មេរៀន និងវិធីសាស្រ្តដែលមាននៅក្នុងឯកសារនោះ វគ្គបណ្តុះបណ្តាលនេះ ពិតជាទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុកជាក់ជាមិនខាន ។

យើងសង្ឃឹមថា ក្រោយពីបានចូលរៀនវគ្គបណ្តុះបណ្តាលនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ នឹងអាចរៀបចំគំរោងមួយដ៏ត្រឹមត្រូវដោយរួមបញ្ចូលទាំងលក្ខខ័ណ្ឌនៃឯកសារគំរោងផងដែរ ។ ជាងនេះទៅទៀត ក្រុមប្រឹក្សាឃុំ សង្កាត់ នឹងមានសមត្ថភាពក្នុងការរៀបចំបញ្ចប់គំរោងថវិការបស់ខ្លួន ។ អ្នកសំរបសំរួលអាចផ្តល់វគ្គបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយនិងអាចជួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងកំឡុងពេលរៀបចំគំរោង បើចាំបាច់ ។

# ផ្នែកទី ១

# មូលដ្ឋាននៃការរៀបចំគំរោងអភិវឌ្ឍន៍ឃុំ សង្កាត់

❖❖❖❖❖❖❖

វគ្គបណ្តុះបណ្តាលនេះមានទំរង់បែបបទជាច្រើនដែលត្រូវបំពេញតាម ក្នុងការអនុវត្តន៍គំរោងអភិវឌ្ឍន៍ ដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។ ប៉ុន្តែជាដំបូង យើងត្រូវកំណត់ និងយល់អោយបានច្បាស់ពីនិយមន័យ និងឧទាហរណ៍មួយចំនួនដូចខាងក្រោម:

## ១.១ និយមន័យនៃគំរោង

ជាទូទៅគំរោង គឺជាសកម្មភាពដែលមានទំនាក់ទំនងគ្នា
ហើយប្រើប្រាស់ ថវិកា ធនធានមនុស្ស មួយកំណត់នៅ ក្នុង
រយៈពេលមួយជាក់លាក់ ដើម្បីឈានទៅសំរេច
ទិសដៅដែលបានកំណត់ ។



គំរោងអភិវឌ្ឍន៍ឃុំ សង្កាត់ គឺជាផែនការសកម្មភាព
ដែលរៀបចំឡើង ដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បី
រួមចំណែកសំរេចអោយបានទិសដៅណាមួយ
នៃកម្មវិធីវិនិយោគឃុំ សង្កាត់ ។

ហេតុនេះគំរោងទាំងឡាយណា ដែលបានកំណត់ នៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ គឺជាគំរោងអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**សូមបញ្ជាក់ថា**

- សកម្មភាពរដ្ឋបាលនៃក្រុមប្រឹក្សាឃុំ សង្កាត់ មិនមែនជាគំរោងទេ ។
- ប្រតិបត្តិការ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ជាប្រចាំ វាក៏មិនមែនជាគំរោងអភិវឌ្ឍន៍ឃុំ សង្កាត់ដែរ ។

ហេតុនេះហើយ ត្រូវតែមានសេចក្តីណែនាំស្តីពីការកសាងផែនការ និងការអនុវត្តន៍នៃប្រភេទសកម្មភាពទាំងនេះ ។

យើងសង្ឃឹមថានៅឆ្នាំ ២០០៣ គំរោងភាគច្រើនដែលអនុវត្តន៍ដោយក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាគំរោង ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ដោយប្រើប្រាស់មូលនិធិឃុំ សង្កាត់ ផ្នែកអភិវឌ្ឍន៍ ។ ហេតុនេះ វគ្គបណ្តុះបណ្តាលនេះនឹង សង្កត់ធ្ងន់លើគំរោងប្រភេទនេះ ។ ទោះបីយ៉ាងណា យើងក៏មិនភ្លេចទេថា ទៅអនាគត នឹងមានប្រភេទគំរោង ផ្សេងៗទៀត ដូចជា:

- គំរោងមិនមែនហេដ្ឋារចនាសម្ព័ន្ធ
- គំរោងដែលប្រើមូលនិធិពីប្រភពផ្សេងទៀត ដូចជាថវិកាដែលបានមកពីការប្រមូលពន្ធមូលដ្ឋាន ។



**ចំណាំ**

ពេលវេលាសំរាប់អនុវត្តគំរោងអាចមានរយៈពេលច្រើនជាងមួយឆ្នាំ ។ ប្រសិនបើគំរោងមានទំហំធំពេកសំរាប់អនុវត្តក្នុងរយៈពេលមួយឆ្នាំ នោះក្រុមប្រឹក្សាអាចធ្វើការសំរេចអោយអនុវត្តតាមផ្នែកនៃគំរោង ក្នុងឆ្នាំនីមួយៗ សំរាប់រយៈពេល ២ ឬ ៣ ឆ្នាំ ។

## ១.២ គំរោងដែលអាចទទួលបានមូលនិធិឃុំ សង្កាត់ ផ្នែកអភិវឌ្ឍន៍



ធនធានមូលនិធិឃុំ សង្កាត់ អាចប្រើប្រាស់បានសំរាប់ តែចំណាយលើសកម្មភាព ដែលបានបញ្ចូលក្នុងគំរោង ថវិកាប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

គំរោងថវិកានេះត្រូវមានការត្រួតពិនិត្យ អនុលោមភាព និងបញ្ជាក់ទទួលស្គាល់ដោយ អភិបាលខេត្ត/ក្រុង។ មូលនិធិឃុំ សង្កាត់ មាន ២ ផ្នែក:

**ផ្នែករដ្ឋបាលទូទៅ:**

គឺជាតំលៃប្រតិបត្តិការដែលរួមមានប្រាក់ខែ ការចំណាយរដ្ឋបាល អាគារ និងឧបករណ៍/សំភារៈ សំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។ និង ។ល។

**ផ្នែកអភិវឌ្ឍន៍:**

ការចំណាយមូលនិធិផ្នែកអភិវឌ្ឍន៍មូលដ្ឋាន បានកំណត់ច្បាស់លាស់ ទាំងការចំណាយចរន្ត និងការចំណាយមូលធន សំរាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន (លើកលែងសំភារៈរដ្ឋបាល) និងការផ្តល់សេវាកម្មសេដ្ឋកិច្ច សង្គម នៅឃុំ សង្កាត់ (លើកលែង សេវាអត្រានុកោលដ្ឋាន និងសេវារដ្ឋបាលទូទៅ ផ្សេងទៀត) ដែលត្រូវរ៉ាប់រង ដោយក្រុមប្រឹក្សា ។ ចំណាយទាំងនោះរួមមាន :

- ការអង្កេត គំនូសប្លង់ ការសាងសង់ ការជួសជុល និង ការថែទាំផ្លូវ ផ្សារ មណ្ឌលសុខភាព សាលារៀន មជ្ឈមណ្ឌលសហគមន៍ សំណង់ប្រព័ន្ធធារាសាស្ត្រ ឃ្លាំងស្តុកកសិផល ប្រព័ន្ធផ្គត់ផ្គង់ទឹក និង ថាមពល និង ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច សង្គម ផ្សេងទៀត ។
- ចំណាយលើបុគ្គលិក និងចំណាយចរន្ត ដែលពាក់ព័ន្ធនឹងប្រតិបត្តិការ និងការថែទាំ ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងការផ្តល់សេវាផ្សេងៗ ។
- ចំណាយគាំទ្រកម្មវិធីអភិវឌ្ឍន៍សហគមន៍ដែលចាត់ចែងដោយអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុក និងអង្គការជួយសហគមន៍ រួមបញ្ចូលនូវយុទ្ធនាការផ្សព្វផ្សាយ និងអប់រំស្ត្រី

និងយុវជន  ការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ និងកម្មវិធីដទៃទៀត ដែលមានឥទ្ធិពលដល់សុខុមាលភាពសង្គម និងប្រជាពលរដ្ឋនៅមូលដ្ឋាន ។

➻ ចំណាយលើការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវយកពីផ្នែកអភិវឌ្ឍន៍នៃមូលនិធិឃុំ សង្កាត់ ។

➻ មូលនិធិឃុំ សង្កាត់ ផ្នែកអភិវឌ្ឍន៍ អាចចំណាយលើការចំណាយមូលធន និងការចំណាយចរន្ត ។



ការចំណាយមូលធនផ្នែកអភិវឌ្ឍន៍ គឺជាការវិនិយោគ ដើម្បីបានទ្រព្យសម្បត្តិ ដែលប្រើប្រាស់ជាប់បានយូរ ។

ជាទូទៅ ប្រសិនបើក្រុមប្រឹក្សាចំណាយថវិកាលើអ្វីមួយនៅឆ្នាំនេះ ហើយអាចប្រើប្រាស់បានដល់ឆ្នាំក្រោយៗទៀត នេះហើយ គឺជាការចំណាយមូលធន ឧទាហរណ៍ ទិញម៉ាស៊ីនបូមទឹក គឺជាការចំណាយមូលធនផ្នែកអភិវឌ្ឍន៍ ។ ប្រសិនបើក្រុម ប្រឹក្សាទិញម៉ាស៊ីនបូមទឹកឆ្នាំនេះ វានឹងនៅតែអាចប្រើប្រាស់សំរាប់បូមទឹកបាននៅឆ្នាំក្រោយទៀត ។ ម៉ាស៊ីនបូមទឹក នៅតែមានតំលៃរហូតដល់ចុងឆ្នាំ ។

ការចំណាយចរន្ត ផ្នែកអភិវឌ្ឍន៍ គឺជាការចំណាយដែលមិនអាចបង្កើតបានជាទ្រព្យសម្បត្តិមានតំលៃឡើយ ។



ប្រសិន បើយើងចង់បានប្រយោជន៍ដូចគ្នានៅឆ្នាំក្រោយ យើងត្រូវតែចំណាយថវិកាបន្ថែមទៀត។

ឧទាហរណ៍ ប្រេងម៉ាស៊ូតសំរាប់ម៉ាស៊ីនបូមទឹក ។ ប្រសិនបើ យើងចង់ប្រើម៉ាស៊ីនបូមទឹកដើម្បីស្រោចស្រពវាលស្រែ យើងត្រូវចំណាយថវិកាដើម្បីទិញប្រេង ។ ប្រសិនបើ យើងចង់ប្រើម៉ាស៊ីនបូមទឹក ដើម្បីស្រោចស្រពវាលស្រែម្តងទៀតនៅឆ្នាំក្រោយ យើងត្រូវចំណាយថវិកាជាច្រើនដើម្បីទិញប្រេងម្តងទៀត ។

ក្រុមប្រឹក្សាត្រូវចំណាយយ៉ាងតិចបំផុត ៨០% នៃមូលនិធិឃុំ សង្កាត់ ផ្នែកអភិវឌ្ឍន៍ លើការចំណាយមូលធន ។ ការចំណាយមូលធន ផ្នែកអភិវឌ្ឍន៍ មានពីរបែបគឺ:

- គំរោងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន

- ទិញសំភារៈសំរាប់ប្រើប្រាស់ក្នុងគំរោងមិនមែនជាហេដ្ឋារចនាសម្ព័ន្ធ

ក្រុមប្រឹក្សាអាចចំណាយយ៉ាងច្រើនបំផុត ២០% លើការចំណាយចរន្ត នៃមូលនិធិឃុំ សង្កាត់ ផ្នែកអភិវឌ្ឍន៍។ អនុក្រឹត្យ និងសេចក្តីណែនាំពីមូលនិធិឃុំ សង្កាត់ ចែងថា ការចំណាយចរន្តរួមមានៈ

(ក) តំលៃនៃការថែរក្សា និងប្រតិបត្តិការសេដ្ឋកិច្ច និងសង្គម ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដែលគ្រប់គ្រង ដោយក្រុមប្រឹក្សា ។

(ខ) តំលៃនៃគាំទ្រកម្មវិធីអភិវឌ្ឍន៍សហគមន៍ ដែលចាត់ចែងដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការជួយសហគមន៍ រួមបញ្ចូលនូវយុទ្ធនាការផ្សព្វផ្សាយ និងអប់រំស្ត្រី និងយុវជននៅមូលដ្ឋាន ការការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ និងកម្មវិធីដទៃទៀត ដែលមាន ឥទ្ធិពលដល់ សុខុមាលភាព សង្គម និងប្រជាពលរដ្ឋនៅមូលដ្ឋាន ។

(គ) តំលៃនៃការរៀបចំ និងកែសំរួលផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។



## ១.៣ និយមន័យនៃគំរោងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន



គំរោងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន គឺជាគំរោង ដែលបង្កើតបានជាអចលនៈទ្រព្យ ដែលស្ថិតនៅមួយកន្លែងហើយ ប្រជាជនទាំងអស់នៅមូលដ្ឋាននោះអាចប្រើប្រាស់បាន ។



"នៅមូលដ្ឋាន " មានន័យថាគឺ ទូទាំងឃុំ (ឧទាហរណ៍ គំរោងផ្លូវ) ឬក៏មួយផ្នែកនៃភូមិ (ឧទាហរណ៍ អណ្តូងទឹក) ប៉ុន្តែមិនមានន័យថា គឺជាផ្ទះមួយនោះទេ ។ ផ្នែកនានានៃហេដ្ឋារចនាសម្ព័ន្ធ ដែលត្រូវបានប្រើប្រាស់ដោយផ្ទះមួយ (ឧទាហរណ៍ ការភ្ជាប់បណ្តាញអគ្គីសនីនៅផ្ទះមួយ) ត្រូវតែចំណាយដោយម្ចាស់ផ្ទះនោះ ។

ឧទាហរណ៍មួយចំនួននៃហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន រួមមាន:

∅ ផ្លូវដែលបំរើអោយប្រជាជននៅក្នុងឃុំ/សង្កាត់ (ទៅផ្សារ សាលារៀន មណ្ឌលសុខភាព ។ល។) ឬក៏ផ្លូវតភ្ជាប់ទៅទីរួមស្រុក ឬទីរួមខេត្ត និងស្ពាន លូ និងសំណង់ដទៃទៀត ។

∅ ការផ្គត់ផ្គង់ទឹក ដូចជា អណ្តូង ស្រះ អាងទឹក ឬក៏បណ្តាញទឹកស្អាត សំរាប់ប្រើប្រាស់នៅតាមផ្ទះ ក្នុងមូលដ្ឋាន ។

∅ អនាម័យសាធារណៈ និងប្រព័ន្ធបង្ហូរទឹកស្អុយ ។

∅ ប្រព័ន្ធធារាសាស្ត្រ លើកលែងតែម៉ាស៊ីនបូមទឹកចល័ត

∅ បង្កើតប្រព័ន្ធ និងបណ្តាញចែកចាយអគ្គីសនីសំរាប់ប្រើប្រាស់តាមផ្ទះនៅក្នុងឃុំ ។

∅ សាងសង់ផ្សារ ឬក៏បង្កើតទីតាំងផ្សារ ។

∅ សាងសង់សាលារៀន

∅ មណ្ឌលសុខភាព

∅ សាងសង់អាគារផ្សេងៗដែលបំរើអោយសហគមន៍ ប៉ុន្តែមិនបំរើអោយនយោបាយ សាសនា ការងាររដ្ឋបាលរបស់ក្រុមប្រឹក្សាឃុំ និងលំនៅដ្ឋានឯកជនឡើយ ។

∅ បណ្តាញផ្គត់ផ្គង់ទឹក និងអនាម័យតាមអាគារសាធារណៈ ដូចជាទីផ្សារ សាលារៀន មណ្ឌលសុខភាព

∅ សាងសង់កន្លែងដាក់សំរាម (ឧទាហរណ៍ ឡដុតសំរាមនៅទីផ្សារ)

∅ សាងសង់កន្លែងគាំទ្រគំរោងការការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ។

ប្រភេទនៃអាគារ ឬសំណង់ផ្សេងទៀតក៏អាចប្រើប្រាស់មូលនិធិឃុំ សង្កាត់ ផ្នែកអភិវឌ្ឍន៍បានដែរ ។

**លើកលែងតែ**

- អាគារ ឬសំណង់ដែលប្រើប្រាស់សំរាប់រដ្ឋបាលក្រុមប្រឹក្សាឃុំ សង្កាត់ ឬក៏ប៉ុស្តិ៍នគរបាល ។
- អាគារ ឬសំណង់ដែលបំរើអោយគណបក្សនយោបាយណាមួយ ។

## ១.៤ លក្ខខណ្ឌក្នុងការប្រើប្រាស់មូលនិធិឃុំ សង្កាត់ ផ្នែកអភិវឌ្ឍន៍

គំរោងហេដ្ឋារចនាសម្ព័ន្ធភាគច្រើន គឺជាការជួសជុលហេដ្ឋារចនាសម្ព័ន្ធចាស់ដែលមានស្រាប់ ជំនួសអោយ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ។ ដូច្នេះប្រភេទគំរោងជួសជុលហេដ្ឋារចនាសម្ព័ន្ធខ្លះ គួរត្រូវបានពិចារណាថា ជាការចំណាយមូលធន ។

ខាងក្រោមនេះជាប្រភេទគំរោងហេដ្ឋារចនាសម្ព័ន្ធដែលជាគំរោងចំណាយមូលធនៈ

∅ ការសាងសង់ថ្មី

∅ ការជួសជុសដែលអាចប្រើប្រាស់បានក្នុងរយៈពេល ៥ ឆ្នាំ ។ នេះរួមបញ្ចូលទាំងការថែទាំផ្លូវតាម កាលកំណត់ ។

∅ ការជួសជុសបន្ទាន់ ឧទាហរណ៍ ដូចជាការខូចខាតដោយសារទឹកជំនន់ ។



សកម្មភាពថែទាំ ដែលត្រូវតែធ្វើច្រើនជាងមួយដងក្នុងរយៈពេល៥ឆ្នាំ គួរពិចារណាថាជាការថែទាំជាប្រចាំ។
សកម្មភាពទាំងនេះ គឺជាការចំណាយចរន្ត ។

**ខាងក្រោមនេះជាលក្ខខ័ណ្ឌនៃការចំណាយមូលធនលើគំរោងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន :**

- នៅនឹងមួយកន្លែង
- ប្រើប្រាស់ដោយគ្រួសារភាគច្រើន (ច្រើនជាងមួយគ្រួសារ)
- មិនមែនអាគារការិយាល័យសំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ឡើយ
- មិនមែនជាសំណង់សំរាប់នគរបាល ឬយោធាឡើយ
- មិនមែនជាសំណង់សំរាប់គណបក្សនយោបាយឡើយ
- អាចប្រើប្រាស់បានយ៉ាងតិច ៥ឆ្នាំ

## ១.៥ សកម្មភាពនានាក្នុងការរៀបចំគំរោង

ការរៀបចំគំរោងមានន័យថាគឺជាសកម្មភាពទាំងឡាយដែលកើតឡើង បន្ទាប់ពីគំរោងត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ និងមុនពេលការចាប់ផ្តើមដំណើរការដេញថ្លៃ ។

**ការរៀបចំគំរោងរួមមានសកម្មភាពដូចខាងក្រោម:**

- ការសិក្សាគំរោង
  ការប្រមូលពត៏មានទាំងអស់ដែលត្រូវការដើម្បីរៀបចំផែនការគំរោង
- ការគ្រោងប្លង់ និងប៉ាន់ស្មានតំលៃ
- ការរៀបចំសហគមន៍ដែលនឹងត្រូវប្រតិបត្តិការ និងថែទាំហេដ្ឋារចនាសម្ព័ន្ធ (ឧទាហរណ៍ សហគមន៍ កសិករប្រើប្រាស់ទឹក) ។
- ការផ្ញើពត៌មានស្តីពីគំរោងទៅអង្គភាពរដ្ឋបាលមូលដ្ឋាន
- ការបញ្ជាក់ទទួលស្គាល់ពីមន្ទីរជំនាញលើគំរោងទាំងនោះ

## ១.៦ ពេលវេលានៃការរៀបចំគំរោង

បន្ទាប់ពីកម្មវិធីវិនិយោគឃុំ សង្កាត់ ត្រូវបានអនុម័ត មេឃុំ ចៅសង្កាត់ គួរពិភាក្សាពីគំរោងដែលមានក្នុងកម្មវិធីវិនិយោគ ជាមួយនិងមន្ត្រីគាំទ្របច្ចេកទេស ។ ពួកគេត្រូវរៀបចំផែនការសកម្មភាពសំរាប់រៀបចំគំរោង ។ ផែនការសកម្មភាពត្រូវរៀបចំសំរាប់សិក្សាគំរោងទាំងអស់ ដែលមានក្នុងកម្មវិធីវិនិយោគ សំរាប់រយៈពេល ៣ឆ្នាំ មិនមែនតែគំរោងដែលនឹងត្រូវអនុវត្តនៅឆ្នាំទី ១ នោះទេ ។

សំរាប់គំរោងខ្លះ ពេលវេលាសិក្សាគំរោងនឹងមានរយៈពេលខ្លី ។ ឧទាហរណ៍ ប្រសិនបើគំរោងគឺជាការសាងសង់បន្ទប់រៀនថ្មី នៅក្នុងសាលាដែលមានស្រាប់ ការសិក្សាគំរោងប្រហែលជា នឹងបញ្ចប់ក្នុងរយៈពេល ១ ឬ ២ ថ្ងៃ ប៉ុណ្ណោះ ។ តែបើគំរោងគឺជាការសាងសង់ប្រព័ន្ធធារាសាស្ត្រ ពេលវេលានៃការសិក្សាគំរោង និងការរៀបចំគំរោង ប្រហែលជាច្រើនជាង ១ ឆ្នាំ ។

- មន្ត្រីគាំទ្របច្ចេកទេស អាចធ្វើសកម្មភាពសិក្សាគំរោង បានគ្រប់ពេលវេលា អាស្រ័យលើអ្វីដែលសមស្រប និងនៅពេលដែលពួកគេមានពេលវេលាសមស្រប ។
- សំរាប់សកម្មភាពគំរោងដែលនឹងអនុវត្តនៅឆ្នាំបន្ទាប់ ទំរង់បែបបទពត៌មានគំរោងត្រូវផ្ញើទៅអង្គភាពរដ្ឋបាលមូលដ្ឋាន អោយបានមុនថ្ងៃទី ៣១ ខែ ធ្នូ ។
- ប្រសិនបើគំរោងមានសកម្មភាពច្រើនជាង ១ឆ្នាំ នោះវាមិនតំរូវអោយធ្វើការសិក្សាគំរោង ២ ដងនោះទេ ។

**ឧទាហរណ៍**

| | |
|---|---|
| ខែ កញ្ញា ២០០២ | ក្រុមប្រឹក្សាឃុំ អនុម័តផែនការវិនិយោគ រួមមានគំរោងផ្លូវដែលមានលូ ស្ពាន និងក្រាល គ្រួសក្រហម ។ ការដាក់លូនឹងអនុវត្តនៅឆ្នាំ ២០០៣ ការសាងសង់ស្ពាននឹងធ្វើនៅឆ្នាំ ២០០៤ និងការក្រាលគ្រួសក្រហម ធ្វើនៅឆ្នាំ ២០០៥ ។ |
| ខែ តុលា - វិច្ឆិកា ២០០២ | អ្នកគាំទ្របច្ចេកទេសអនុវត្តការសិក្សាគំរោងសំរាប់គំរោងទាំងស្រុង។ |
| ខែ ធ្នូ ២០០២ | មេឃុំ ផ្ញើពត៌មានគំរោង ដល់អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ។ |
| ខែ មករា ២០០៣ | ការិយាល័យផ្លូវលំជនបទនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បញ្ជាក់បច្ចេកទេសលើគំរោង ។ |
| ២០០៣ | ដាក់លូ |
| ២០០៤ | សាងសង់ស្ពាន |
| ២០០៥ | ក្រាលគ្រួសក្រហម |

# ផ្នែកទី ២

# តួនាទី និងភារកិច្ច របស់អ្នកពាក់ព័ន្ធ

❶❷❸❹❺❻❼❽❾

## ២.១ ក្រុមប្រឹក្សាឃុំ សង្កាត់

**ក្រុមប្រឹក្សា គឺជាអ្នកធ្វើសេចក្តីសំរេច !**



ក្រុមប្រឹក្សា នឹងប្រជុំដើម្បីធ្វើការ
សំរេចលើបញ្ហា ដូចខាងក្រោម:

- អនុម័តផែនការអភិវឌ្ឍន៍ និងធ្វើការកែសំរួលផែនការអភិវឌ្ឍន៍
- អនុម័តកម្មវិធីវិនិយោគ រួមទាំងការសំរេចលើកទី ១ ថាតើមូលនិធិឃុំ សង្កាត់ ផ្នែកអភិវឌ្ឍន៍ ត្រូវចំណាយយ៉ាងដូចម្តេច ។
- អនុម័តសេចក្តីព្រាងគំរោងថវិកាដែលបានដាក់ជូនទៅអភិបាលខេត្ត/ក្រុង និងការកែសំរួលគំរោងថវិកា ។
- ធ្វើការតាមដាន និងវាយតំលៃលទ្ធផល និងផលប៉ះពាល់ នៃគំរោងដែលប្រើប្រាស់ថវិកាផ្នែកអភិវឌ្ឍន៍ ។
- បង្កើតយន្តការ ដើម្បីធានាការចូលរួមរបស់សហគមន៍អោយបានច្រើន ក្នុងការអនុវត្តន៍គំរោង ។

ទោះជាយ៉ាងណាក៏ដោយ ការសំខាន់គឺត្រូវយល់ថាតួនាទីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រជុំដើម្បីធ្វើការសំរេច មិនមែនអនុវត្តសេចក្ដីសំរេចឡើយ ។ ការអនុវត្តន៍សេចក្ដីសំរេចគឺជាភារកិច្ចរបស់មេឃុំ ចៅសង្កាត់ ។

## ២.២ គណៈកម្មាធិការកសាងផែនការ និងថវិកា



គណៈកម្មាធិការកសាងផែនការ និងថវិកា គឺជាគណៈកម្មាធិការផ្ដល់យោបល់ដែលជួយមេឃុំ ចៅសង្កាត់ ក្នុងការធ្វើសេចក្ដីព្រាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងគំរោងថវិកា ។

គណៈកម្មាធិការកសាងផែនការ និងថវិកា មិនមានតួនាទីអ្វីក្នុងការអនុវត្តន៍គំរោងឡើយ ។

## ២.៣ មេឃុំ ចៅសង្កាត់

មេឃុំ ចៅសង្កាត់ មានភារកិច្ចគ្រប់គ្រងការអនុវត្តន៍គំរោង ដែលមាននៅក្នុងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ



នៅក្នុងដំណាក់កាលនៃការរៀបចំគំរោង មេឃុំ ចៅសង្កាត់ នឹងទទួលខុសត្រូវក្នុងការគ្រប់គ្រងសិក្សា គំរោង និង សំរប សំរួលការងារក្នុងការរៀបចំគំរោង ។

នៅពេលសិក្សាគំរោងត្រូវបានបញ្ចប់ មេឃុំ ចៅសង្កាត់ នឹងផ្ញើពត៌មានពីគំរោងទាំងអស់ទៅអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត/ក្រុង ។

## ២.៤ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ និងស្ថាប័នសង្គមស៊ីវិល

- ស្ថាប័នសង្គមស៊ីវិល គឺជាស្ថាប័នទាំងឡាយណា ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងពីរដ្ឋាភិបាល ហើយមានសកម្មភាពនៅក្នុងឃុំ សង្កាត់ ។





- គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ គឺជាគណៈកម្មាធិការដែលបង្កើតឡើង ដោយការជ្រើសរើសពីប្រជាជននៅក្នុងភូមិ ដើម្បីរៀបចំសកម្មភាពអភិវឌ្ឍន៍នៅក្នុងភូមិ ។ នៅក្នុងភូមិដែលមានគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ សមាសភាពនៃគណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវមានតំណាងម្នាក់ពីអាជ្ញាធរភូមិ និងតំណាងម្នាក់ពីគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ តំណាងទាំងពីរខាងលើនេះត្រូវមានបុរសម្នាក់ នារីម្នាក់ (យោងតាមប្រកាសអន្តរក្រសួងស្តីពីការកែសំរួលប្រការ ២៩ នៃប្រកាសអន្តរក្រសួង ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់) ។

សំរាប់ប្រភេទគំរោងភាគច្រើន ប្រតិបត្តិការ និងការថែទាំសមិទ្ធិផលគំរោងអាចជាភារកិច្ចនៃស្ថាប័នសង្គមស៊ីវិល ។ ឧទាហរណ៍:

- គំរោងអណ្តូងទឹក: គណៈកម្មការគាំទ្រអណ្តូង
- គំរោងធារាសាស្ត្រ: សហគមន៍កសិករប្រើប្រាស់ទឹក
- គំរោងសាលារៀន: គណៈកម្មការមាតាបិតា - គ្រូបង្រៀន



☛ សំរាប់គំរោងជាច្រើនទៀត ប្រសិនបើ គណៈកម្មការមិនទាន់បានបង្កើត វាគួរតែរៀបចំបង្កើត នៅដំណាក់កាលចាប់ផ្តើមរៀបចំគំរោង ។

☛ បន្ទាប់មក គណៈកម្មការ និង សមាជិកចូលរួមជួយសិក្សា និងជ្រើសរើសប្លង់ និងទីកន្លែងគំរោង ។ (ឧទាហរណ៍ តើគួរជីកអណ្តូង នៅកន្លែងណា?) ។

ទោះជាយ៉ាងណាក៏ដោយ ការសំខាន់គឺត្រូវយល់ថាតួនាទីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រជុំដើម្បីធ្វើការសំរេច មិនមែនអនុវត្តសេចក្តីសំរេចឡើយ ។ ការអនុវត្តន៍សេចក្តីសំរេចគឺជាភារកិច្ចរបស់មេឃុំ ចៅសង្កាត់ ។

## ២.២ គណៈកម្មាធិការកសាងផែនការ និងថវិកា



គណៈកម្មាធិការកសាងផែនការ និងថវិកា គឺជាគណៈកម្មាធិការផ្តល់យោបល់ដែលជួយមេឃុំ ចៅសង្កាត់ ក្នុងការធ្វើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងគំរោងថវិកា ។

គណៈកម្មាធិការកសាងផែនការ និងថវិកា មិនមានតួនាទីអ្វីក្នុងការអនុវត្តន៍គំរោងឡើយ ។

## ២.៣ មេឃុំ ចៅសង្កាត់

មេឃុំ ចៅសង្កាត់ មានភារកិច្ចគ្រប់គ្រងការអនុវត្តន៍គំរោង ដែលមាននៅក្នុងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ



- នៅក្នុងដំណាក់កាលនៃការរៀបចំគំរោង មេឃុំ ចៅសង្កាត់ នឹងទទួលខុសត្រូវក្នុងការគ្រប់គ្រងសិក្សា គំរោង និង សំរប សំរួលការងារក្នុងការរៀបចំគំរោង ។

- នៅពេលសិក្សាគំរោងត្រូវបានបញ្ចប់ មេឃុំ ចៅសង្កាត់ នឹងផ្ញើពត៌មានពីគំរោងទាំងអស់ទៅអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត/ក្រុង ។

## ២.៤ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ និងស្ថាប័នសង្គមស៊ីវិល

- ស្ថាប័នសង្គមស៊ីវិល គឺជាស្ថាប័នទាំងឡាយណា ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងពីរដ្ឋាភិបាល ហើយមានសកម្មភាពនៅក្នុងឃុំ សង្កាត់ ។





- គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ គឺជាគណៈកម្មាធិការដែលបង្កើតឡើង ដោយការជ្រើសរើសពីប្រជាជននៅក្នុងភូមិ ដើម្បីរៀបចំសកម្មភាពអភិវឌ្ឍន៍នៅក្នុងភូមិ ។ នៅក្នុងភូមិដែលមានគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ សមាសភាពនៃគណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវមានតំណាងម្នាក់ពីអាជ្ញាធរភូមិ និងតំណាងម្នាក់ពីគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ តំណាងទាំងពីរខាងលើនេះត្រូវមានបុរសម្នាក់ នារីម្នាក់ (យោងតាមប្រកាសអន្តរក្រសួងស្តីពីការកែសំរួលប្រការ ២៩ នៃប្រកាសអន្តរក្រសួង ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់) ។

សំរាប់ប្រភេទគំរោងភាគច្រើន ប្រតិបត្តិការ និងការថែទាំសមិទ្ធិផលគំរោងអាចជាភារកិច្ចនៃស្ថាប័នសង្គមស៊ីវិល ។ ឧទាហរណ៍:

- គំរោងអណ្តូងទឹក: គណៈកម្មការគាំទ្រអណ្តូង
- គំរោងធារាសាស្ត្រ: សហគមន៍កសិករប្រើប្រាស់ទឹក
- គំរោងសាលារៀន: គណៈកម្មការមាតាបីតា - គ្រូបង្រៀន



☛ សំរាប់គំរោងជាច្រើនទៀត ប្រសិនបើ គណៈកម្មការមិនទាន់បានបង្កើត វាគួរតែរៀបចំបង្កើត នៅដំណាក់កាលចាប់ផ្តើមរៀបចំគំរោង ។

☛ បន្ទាប់មក គណៈកម្មការ និង សមាជិកចូលរួមជួយសិក្សា និងជ្រើសរើសប្លង់ និងទីកន្លែងគំរោង ។ (ឧទាហរណ៍ តើគួរជីកអណ្តូង នៅកន្លែងណា?) ។

## ២.៥ សហគមន៍ និងអ្នកទទួលផលពីគំរោង

សហគមន៍មានន័យថាជាប្រជាជនទាំងអស់ដែលរស់នៅក្នុងឃុំ សង្កាត់ ។

អ្នកទទួលផលប្រយោជន៍ដោយផ្ទាល់ពីគំរោង គឺជាប្រជាជន និងក្រុមគ្រួសារ ដែលប្រើប្រាស់សមិទ្ធិផល ពីគំរោងដោយផ្ទាល់ ។ ឧទាហរណ៍ អ្នកទទួលផលប្រយោជន៍ដោយផ្ទាល់ពីអណ្តូងទឹក គឺជាសមាជិកទាំងអស់ នៅក្នុងគ្រួសារដែលប្រើប្រាស់ទឹកអណ្តូង មិនមែនគ្រាន់តែអ្នកដែលដើរទៅដងទឹកអណ្តូងនោះឡើយ ។ អ្នកទទួលផលប្រយោជន៍ដោយផ្ទាល់ពីសាលារៀន គឺសមាជិកទាំងអស់នៅក្នុងគ្រួសារ ដែលបានបញ្ជូនកូនទៅសាលារៀន មិនមែនតែកុមារដែលទៅសាលារៀននោះទេ ។

អ្នកទទួលផលដោយផ្ទាល់គួរចូលរួមអោយបានច្រើនតាមដែលអាចធ្វើទៅបានក្នុងការជ្រើសរើសគំនូសប្លង់សំរាប់គំរោង និងក្នុងការតាមដានការអនុវត្តន៍គំរោង ។

## ២.៦ ផ្នែករដ្ឋបាលមូលដ្ឋាន

ផ្នែករដ្ឋបាលមូលដ្ឋានដែលមានអ្នកសំរបសំរួលខេត្ត ស្រុក ជួយពង្រឹងសមត្ថភាព និងគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីអនុវត្តតួនាទី របស់ពួកគេ ក្នុងការរៀបចំគំរោង ។ ហេតុនេះ តួនាទីសំខាន់របស់អ្នកសំរបសំរួលស្រុកគឺគ្រាន់តែជាអ្នកផ្តល់យោបល់ដល់ឃុំ សង្កាត់ ប៉ុណ្ណោះ ។ អ្នកសំរបសំរួលស្រុកមិនមែនជាអ្នកធ្វើសកម្មភាពរៀបចំគំរោង របស់ឃុំ សង្កាត់ ដោយខ្លួនឯងឡើយ ។

> អ្នកសំរបសំរួលស្រុក (ឬក៏មន្ត្រីដទៃទៀត) មិនត្រូវចូលរួមធ្វើសកម្មភាពណាមួយ ក្នុងការប្រមូលទុនបដិភាគពីប្រជាជនជាដាច់ខាត ។

## ២.៧ ផ្នែកគាំទ្របច្ចេកទេស

នៅតាមខេត្ត/ក្រុង ដែលមានផ្នែកគាំទ្របច្ចេកទេស មន្ត្រីគាំទ្របច្ចេកទេស នឹងដើរតួនាទីជាអ្នកជំនួយការបច្ចេកទេស ដល់ឃុំ សង្កាត់ ក្នុងការរៀបចំគំរោងភាគច្រើន ។




- ផ្តល់ការណែនាំដល់គណៈកម្មាធិការកសាងផែនការ និងថវិកា លើគំរោងសមស្រប ដែលអាចសំរេចបាននូវគោលបំណងផែនការ និងប៉ាន់ស្មានតំលៃគំរោង នៅក្នុង ជំហានទី ៥ នៃការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។
- អនុវត្តការសិក្សាលទ្ធភាពគំរោងជាជំហានដំបូង
- រៀបចំគំនូសប្លង់គំរោង
- ប៉ានស្មានតំលៃគំរោង
- បំពេញផ្នែកពត៌មានបច្ចេកទេសនៃទំរង់បែបបទពត៌មានគំរោង
- ត្រូវចុះហត្ថលេខាលើទំរង់បែបបទពត៌មានគំរោង ជាមួយ មេឃុំ ចៅ សង្កាត់ ដោយបញ្ជាក់ថាគំនូសប្លង់គំរោងនេះពិតជាត្រឹមត្រូវ ។

## ២.៨ អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត/ក្រុង

អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត/ក្រុង នឹងទទួលពត៌មានគំរោងពីមេឃុំ ចៅសង្កាត់ ។




- តើមេឃុំ ចៅសង្កាត់ បានផ្តល់ពត៌មានចំបាច់គ្រប់គ្រាន់ហើយឬនៅ?
- តើគំរោងនេះស្របទៅតាមផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ដែរឬទេ?
- តើគំរោងនេះមានលក្ខណៈសមស្របក្នុងការប្រើប្រាស់មូលនិធិឃុំ សង្កាត់ផ្នែកអភិវឌ្ឍន៍ដែរឬទេ? ឬក៏ផ្ទុយទៅនិងច្បាប់ដែរឬទេ?

☑ បន្ទាប់ពីពិនិត្យរួចរាល់ហើយ អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត/ក្រុង នឹងផ្ញើច្បាប់ចំលងនៃពត៌មានគំរោងទាំងនោះ ទៅមន្ទីរជំនាញពាក់ព័ន្ធ ដើម្បីពិនិត្យបញ្ជាក់ទទួលស្គាល់ថា ពិតជាត្រឹមត្រូវតាមបច្ចេកទេស ។

☑ អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត/ក្រុង ក៏ត្រូវធានាថា ពត៌មានគំរោងទាំងនេះត្រូវបានបញ្ចូល ទៅក្នុងទិន្នន័យមូលដ្ឋាននៃគំរោងមូលនិធិឃុំ សង្កាត់ ។

☑ អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត/ក្រុង ត្រូវរៀបចំការសិក្សាផលប៉ះពាល់បរិស្ថានជាមុន សំរាប់ប្រភេទគំរោងខ្លះ ។

☑ អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត/ក្រុង ត្រូវរៀបចំសិក្សាពីកម្មសិទ្ធដីធ្លី និងរបាយការណ៍ស្តីពីការផ្ទេរកម្មសិទ្ធដីធ្លីដែលជាទីតាំងសំណង់ ជាមុនសិន សំរាប់ប្រភេទគំរោងខ្លះ ។

## ២.៩ មន្ទីរជំនាញនានា

### ក) ជំនួយការក្នុងការរៀបចំគំរោង

សំរាប់ប្រភេទគំរោងខ្លះ បណ្តាមន្ទីរជំនាញពាក់ព័ន្ធ ត្រូវចូលរួមជាជំនួយបច្ចេកទេស ក្នុងការរៀបចំគំរោង ។




- ការណែនាំបច្ចេកទេសលើគំនូសប្លង់នៃគំរោង ឧទាហរណ៍ គំនូសប្លង់នៃគំរោងធារាសាស្រ្តត្រូវការជំនាញបច្ចេកទេសពីមន្ទីរជំនាញនានាប្រសិនបើអ្នកគាំទ្របច្ចេកទេសមិនមានសមត្ថភាពគ្រប់គ្រាន់ ។ ក្នុងឧទាហរណ៍នេះ អ្នកគាំទ្របច្ចេកទេសគួរស្នើរទៅមន្ទីរធនធានទឹក អោយជួយជាបច្ចេកទេស ។
- ធ្វើកិច្ចសន្យាព្រមព្រៀងពីការរៀបចំគ្រប់គ្រងសំរាប់ប្រតិបត្តិការ និងការថែរទាំសមិទ្ធិផលគំរោង ។ ជាពិសេស សំរាប់គំរោងដែលមន្ទីរជំនាញ ទទួលខុសត្រូវក្នុងការចំណាយសំរាប់ប្រតិបត្តិការ ។ ឧទាហរណ៍ ក្រុមប្រឹក្សាមិនអាចសាងសង់សាលារៀនឡើយ បើមន្ទីរអប់រំ មិនយល់ព្រមក្នុងការ ផ្តល់គ្រូបង្រៀន និងការឧបត្ថម្ភផ្សេងៗនោះ ។

អ្នកគាំទ្របច្ចេកទេសមានភារកិច្ចពិភាក្សាជាមួយមន្ទីរជំនាញ ពីបញ្ហាបច្ចេកទេស ។ ហើយអ្នកសំរបសំរួលស្រុក គួរជួយមេឃុំ ចៅសង្កាត់ ក្នុងការពិភាក្សាជាមួយមន្ទីរជំនាញ ពីបញ្ហាមិនមែនបច្ចេកទេស (ឧទាហរណ៍ ការផ្តល់គ្រូបង្រៀនសំរាប់សាលារៀន) ។

## ខ) ការពិនិត្យ បញ្ជាក់បច្ចេកទេស

បណ្តាមន្ទីរជំនាញមានភារកិច្ចពិនិត្យ បញ្ជាក់បច្ចេកទេស រាល់គំរោងទាំងអស់ ។

អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត/ក្រុង នឹងផ្ញើច្បាប់ចំលងនៃពត៌មានគំរោងទៅមន្ទីរជំនាញ ។ មន្ទីរជំនាញ នឹងពិនិត្យមើលរាល់ពត៌មានទាំងអស់នៃគំរោង ។ ប្រសិនបើមានហេតុផលណាមួយ ដែលមន្ទីរជំនាញពិនិត្យឃើញថា ឃុំ សង្កាត់ មិនអាចអនុវត្តគំរោងបានទេ មន្ទីរជំនាញ ត្រូវតែជូនដំណឹងទៅអង្គភាពរដ្ឋបាលមូលដ្ឋាន ក្នុងរយៈពេល ១៥ ថ្ងៃ បន្ទាប់ពីទទួលបានពត៌មានគំរោង ។ ផ្ទុយទៅវិញ បន្ទាប់ពីរយៈពេល ១៥ ថ្ងៃ ប្រសិនបើមន្ទីរជំនាញមិនមានអ្វីជំទាស់ យើងអាចនិយាយបានថាគំរោងនោះបានពិនិត្យ បញ្ជាក់បច្ចេកទេសត្រឹមត្រូវហើយ ។

**មន្ទីរជំនាញមិនមានសិទ្ធិអនុម័តទេ គឺគ្រាន់តែពិនិត្យ បញ្ជាក់បច្ចេកទេសប៉ុណ្ណោះ !!**

មន្ទីរជំនាញមានសិទ្ធបដិសេធតែមួយគត់ ប្រសិនបើ:

- មានបញ្ហាបច្ចេកទេសក្នុងការគូសប្លង់គំរោង ដែលនឹងបណ្តាលអោយគំរោងបរាជ័យ ឬ
- មានបញ្ហាទំនាស់រវាងផែនការឃុំ និងផែនការមន្ទីរជំនាញ ។ ឧទាហរណ៍ ប្រសិនបើឃុំចង់សង់ សាលារៀន នៅក្នុងភូមិ"ក" ប៉ុន្តែមន្ទីរអប់រំមានផែនការសង់សាលារៀននៅក្នុងភូមិ"ខ" សំរាប់កុមារទាំងពីរភូមិ ។ ប្រសិនបើមានបញ្ហាដូច្នេះ មន្ទីរជំនាញត្រូវពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ ដើម្បីរកដំណោះស្រាយ។

## ២.១០ គណៈកម្មការប្រតិបត្តិ (គ.ប្រ)

តួនាទីរបស់ គ.ប្រ គឺដើម្បីគាំទ្រផ្នែករដ្ឋបាលមូលដ្ឋាន និងផ្នែកគាំទ្របច្ចេកទេស ដើម្បីជួយបច្ចេកទេសដល់ឃុំ សង្កាត់ ។ គ.ប្រ មិនមានតួនាទីដោយផ្ទាល់ ក្នុងការរៀបចំគំរោងឡើយ ហើយក៏មិនមានតួនាទី ទាល់តែសោះក្នុងការអនុម័តគំរោងឃុំ សង្កាត់ ឡើយ ។







# ផ្នែកទី ៣
# ទំរង់បែបបទ ក្នុងការរៀបចំគំរោង

...............

លទ្ធផលនៃដំណើរការរៀបចំគំរោង គឺជាពត៌មានអំពីគំរោង ។ ពត៌មានអំពីគំរោងនេះត្រូវដាក់ជូនទៅអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ដោយភ្ជាប់មកជាមួយនូវឯកសារយោងផ្សេងៗទៀត ។

គ្រប់គំរោងទាំងអស់ដែលប្រើប្រាស់ចំណាយមូលធននៃមូលនិធិឃុំ សង្កាត់ ផ្នែកអភិវឌ្ឍន៍ ត្រូវឱ្យបំពេញទំរង់បែបបទពត៌មានស្តីពីគំរោង ។

ទំរង់បែបបទពត៌មានគំរោងចែកចេញជាច្រើនផ្នែក ដូចខាងក្រោម និងមានភ្ជាប់នូវឯកសារមួយចំនួនទៀត :

## ៣.១. ពត៌មានពីផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

ពត៌មាននេះរួមមាន គោលបំណង ប្រភេទគំរោង លទ្ធផលគ្រោងទុក និងអ្នកទទួលផលពីគំរោង ។ មេឃុំ ចៅសង្កាត់ ត្រូវសរសេរចូលនូវចំនួនអ្នកទទួលផល សំរាប់ភូមិនិមួយៗ ។

## ៣.២. ផែនទីគំរោង

ផែនទីគំរោងត្រូវតែជាផែនទីឃុំ សង្កាត់ ដែលបង្ហាញអំពីទីតាំងនៃលទ្ធផលរបស់គំរោង និងបណ្តាភូមិទាំងឡាយ ដែលអ្នកទទួលផលរស់នៅ ។

## ៣.៣. ប្លង់ការដ្ឋាន

ត្រូវមានប្លង់ការដ្ឋានមួយ ចំពោះលទ្ធផលនិមួយៗនៃគំរោង ។ ប្លង់ការដ្ឋាននឹងបង្ហាញអំពីទីតាំងនៃលទ្ធផល និងពត៌មានផ្សេងៗទៀតនៃគំរោង ។ ឧទាហរណ៍ តើការដ្ឋាននោះជាកន្លែងមានទឹកជំនន់ឬយ៉ាងណា? តើដីនៅការដ្ឋានជា ដីខ្សាច់ ឬដីឥដ្ឋ? ។ល។

## ៣.៤. ពត៌មានបច្ចេកទេស

ពត៌មានបច្ចេកទេសត្រូវបានប្រើ ដើម្បីបង្កើតគំនូរប្លង់សំរាប់គំរោង ។ គំរោងខុសៗគ្នា ចាំបាច់ត្រូវអោយមានប្រភេទពត៌មានខុសៗគ្នាដែរ ទៅតាមប្រភេទគំរោងនីមួយៗ ។

## ៣.៥. ធនធាននៅមូលដ្ឋាន



ផ្នែកនេះពិពណ៌នាអំពីប្រភពធនធានផ្សេងៗ នៅមូលដ្ឋាន ដែលអាចប្រើប្រាស់ ដើម្បីសាងសង់សំណង់ ដូចជា ខ្សាច់ ឈើ ឬក៏ឬស្សី ។ ឧទាហរណ៍ មានថ្មដែលអាចត្រូវបានគេប្រើជំនួសបេតុង ដើម្បី សាងសង់ជញ្ជាំង សំរាប់ដាក់លូ ។

ធនធានដែលមនុស្សអាចផលិតបានក៏មានសារៈសំខាន់ផងដែរ ឧទាហរណ៍ សិប្បកម្មឡអិដ្ឋ ដែលនៅជិតការដ្ឋាននៃគំរោង ។ ប្រសិនបើគំរោងនោះជាគំរោងផ្លូវក្រាលគ្រួសក្រហម អ្នកគាំទ្របច្ចេកទេស គួររកមើលកន្លែងណា ដែលមានគ្រួសក្រហម នៅជិតបំផុត និងមានចំងាយផ្លូវប៉ុន្មានគីឡូម៉ែត្រ សំរាប់ការដឹកជញ្ជូន ។

## ៣.៦. ទីកន្លែងវប្បធម៌ និងបរិស្ថាន



ផ្នែកនេះបង្ហាញថា តើគំរោងនោះ នឹងមានផលប៉ះពាល់យ៉ាងណាលើទីកន្លែងបរិស្ថាន និង វប្បធម៌ ។ បំពោះគំរោងដែលបណ្តាលឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និងវប្បធម៌ ការសិក្សា ពិសេសមួយនឹងត្រូវបានធ្វើឡើង ដែលហៅថា "ការវាយតំលៃផលប៉ះពាល់បរិស្ថាន" ។

☛ ប្រភេទគំរោងដែលតំរូវអោយមានការសិក្សា ការវាយតំលៃផលប៉ះពាល់បរិស្ថាននេះមានដូចជា :

- ការសាងសង់ផ្លូវថ្មី (មិនមែនការជួសជុលផ្លូវចាស់ទេ)
- គំរោងធារាសាស្រ្តថ្មី (មិនមែនការស្តារប្រព័ន្ធធារាសាស្រ្តដែលមានស្រាប់ទេ)

ជាការសំខាន់ណាស់ ដែលមេឃុំ ចៅសង្កាត់ និងមន្ត្រីជំនួយការបច្ចេកទេស ត្រូវគិតគូរយ៉ាងប្រុងប្រយ័ត្នមុនពេលឆ្លើយតបទៅនឹងសំណួរទាំងនោះ។ កុំចេះតែនិយាយថា " គ្មានទេ១ " បើទោះណាជាមានបញ្ហានោះ ។ ប្រសិនបើយើងមិនគិតអំពីបញ្ហានេះក្នុងកំឡុងពេលរៀបចំគំរោង និងស្វែងរកដំណោះស្រាយណាមួយអោយបានល្អទេ នោះប្រហែលជាមានអ្នកលើកបញ្ហានេះឡើង ក្រោយពីអ្នកម៉ៅការ ចាប់ផ្តើមការងាររបស់ខ្លួន ហើយរឿងនេះនឹងបង្កការឈឺក្បាលសំរាប់គ្រប់គ្នាជាក់មិនខានឡើយ ។

## ៣.៧. ការប្រើប្រាស់ដីធ្លីសំរាប់គំរោង



ទំរង់បែបបទនេះត្រូវបង្ហាញពត៌មានអំពីអ្នកដែលជាម្ចាស់កម្មសិទ្ធ និងការប្រើប្រាស់ដី ដែលនឹងត្រូវធ្វើការសាងសង់គំរោង ។ ប្រសិនបើអ្នកណាម្នាក់ បច្ចុប្បន្ននេះ កំពុងកាន់កាប់ដីជាឯកជន អ្នកកាន់កាប់នោះ នឹងត្រូវបាត់បង់សិទ្ធរបស់ខ្លួនក្នុងការកាន់កាប់ និងប្រើប្រាស់ដីនោះ ដោយសារការអនុវត្តន៍គំរោង ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវតែធ្វើកិច្ចព្រមព្រៀងជាមុន ជាមួយនិងអ្នកកាន់កាប់ដីនោះ មុនពេលអនុវត្តគំរោង ។ ទាក់ទងទៅនិងការប្រើប្រាស់ដីធ្លី មានគំរោងបីប្រភេទ ដែលត្រូវធ្វើការពិចារណាគឺ :

១. គំរោងទាំងឡាយណាដែលនឹងត្រូវបានសាងសង់លើដីសាធារណៈ មិនដែលបានប្រើប្រាស់ដោយឯកជន ។ ឧទាហរណ៍ : ការសាងសង់អាគារសិក្សាលើទីធ្លាក្នុងសាលារៀន ដែលមានស្រាប់ ។

២. គំរោងដែលនឹងប្រើប្រាស់ដីតូចៗ កាន់កាប់ដោយឯកជន ប៉ុន្តែពុំមានបុគ្គល ឬគ្រួសារណានឹងបាត់បង់ច្រើនជាង ៥ភាគរយ នៃដីដែលពួកគាត់ធ្វើកសិដ្ឋានឡើយ ។ ឧទាហរណ៍ គំរោងផ្លូវដែលនឹងត្រូវប្រើដីវាលស្រែបន្តិចបន្តួចដែលនៅអមសងខាងផ្លូវ ។
   ចំពោះគំរោងប្រភេទនេះ មេឃុំ ចៅសង្កាត់ ត្រូវរៀបចំរបាយការណ៍មួយដែលនឹងបង្ហាញថាម្ចាស់កម្មសិទ្ធិដី នឹងត្រូវបានគេប្រាប់អោយដឹងអំពីគំរោង ហើយពួកគាត់បានឯកភាពថានឹងសុខចិត្តប្រគល់ដីនោះ សំរាប់គំរោង ។

៣. គំរោងដែលម្ចាស់កម្មសិទ្ធិដី ត្រូវបាត់បង់សិទ្ធិកាន់កាប់លើសពី៥ភាគរយនៃដីដែលគាត់មាន ។

ឧទាហរណ៍ ៖ ការសាងសង់សាលារៀនលើដីវាលស្រែ ។ ចំពោះគំរោងប្រភេទនេះ តំរូវអោយមានរបាយការណ៍ពិសេសមួយដែលហៅថា " របាយការណ៍ពីការផ្ទេរកម្មសិទ្ធដីធ្លី"

## ៣.៨. ពត៌មានលំអិតនៃលទ្ធផលគំរោង និងការប៉ាន់ស្មានតំលៃ



ផ្នែកនេះនឹងត្រូវបានរៀបចំឡើងដោយមន្ត្រីជំនួយការបច្ចេកទេស។ ផ្នែកនេះរួមមាន គ្រោងប្លង់បច្ចេកទេស សំរាប់លទ្ធផលគំរោង ហើយនឹងមានផងដែរនូវតារាងមួយដែលបង្ហាញយ៉ាងលំអិត នូវប្រភេទ និងគុណភាពនៃលទ្ធផលគំរោងនីមួយៗ និងតំលៃប៉ាន់ស្មាន ។

 តំលៃប៉ាន់ស្មានសរុបនៃលទ្ធផលទាំងអស់ គឺជាតំលៃប៉ាន់ស្មាននៃគំរោង ។

## ៣.៩. ប្រតិបត្តិការ និងការថែទាំ

ចំពោះគំរោងនីមួយៗ គួរមានផែនការប្រតិបត្តិការ និងការថែទាំ ។ ផែនការនេះគួរបង្ហាញពី ៖

### ▣ កិច្ចការប្រតិបត្តិ

- ❑ តើមានកិច្ចការសំរាប់ប្រតិបត្តិចាំបាច់ណាខ្លះ?
- ❑ តើនរណាដែលជាអ្នកទទួលខុសត្រូវក្នុងការរៀបចំកិច្ចការប្រតិបត្តិនោះ?
- ❑ តើកិច្ចការប្រតិបត្តិនោះនឹងត្រូវចំណាយអស់តំលៃប៉ុន្មាន?

### ▣ កិច្ចការថែទាំជាប្រចាំ (មួយឆ្នាំម្តង ឬញឹកញាប់ជាងនេះ)

- ❑ តើមានកិច្ចការថែទាំជាប្រចាំណាខ្លះដែលចាំបាច់ត្រូវមាន?
- ❑ តើនរណាដែលជាអ្នកទទួលខុសត្រូវក្នុងការរៀបចំកិច្ចការថែទាំជាប្រចាំនេះ?
- ❑ តើកិច្ចការថែទាំជាប្រចាំនេះត្រូវចំណាយអស់តំលៃប៉ុន្មាន?

### ▣ កិច្ចការថែទាំតាមកាលកំណត់នៃគំរោង (ធ្វើឡើងម្តងសំរាប់រយៈពេលជាងមួយឆ្នាំ)

- ❑ តើមានកិច្ចការថែទាំតាមកាលកំណត់នៃគំរោងអ្វីខ្លះដែលចាំបាច់ត្រូវមាន?
- ❑ តើនរណារដែលជាអ្នកទទួលខុសត្រូវក្នុងការរៀបចំកិច្ចការថែទាំតាមកាលកំណត់នេះ?

- តើការបំពេញកិច្ចការនេះនឹងត្រូវចំណាយអស់តំលៃប៉ុន្មាន?
- តើតំលៃជាមធ្យមក្នុងមួយឆ្នាំ ក្នុងកិច្ចប្រតិបត្តិការ និងការថែទាំលទ្ធផលគំរោង ចំណាយអស់តំលៃប៉ុន្មាន ? (មិនបូកបញ្ចូលតំលៃ ដែលបានមកពីថវិកា របស់រាជរដ្ឋាភិបាល ឧទាហរណ៍ ប្រាក់បៀវត្ស របស់គ្រូបង្រៀន )។
- តើមានការចំណាយប៉ុន្មានក្នុងមួយឆ្នាំ ពីថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់?



# ផ្នែកទី ៤

# របៀបបំពេញទំរង់បែបបទពត៌មានគំរោង

~~~~~~~~~~~~

## ៤.១. ការបំពេញទំរង់បែបបទពត៌មានគំរោង

ទំរង់បែបបទពត៌មានគំរោងត្រូវចុះហត្ថលេខាដោយមនុស្សបីនាក់ គឺ:

- មេឃុំ ចៅសង្កាត់ ដែលជាអ្នកទទួលខុសត្រូវក្នុងការរៀបចំប្រមូលពត៌មានសំរាប់ បំពេញក្នុងទំរង់បែបបទ ហើយបញ្ជូនទៅអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ។
- មន្ត្រីគាំទ្របច្ចេកទេស ជាអ្នកទទួលខុសត្រូវក្នុងការធានាថា ពត៌មានបច្ចេកទេស ដែលបានបំពេញ ក្នុងទំរង់បែបបទនេះមានភាពត្រឹមត្រូវ ។
- មន្ត្រីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ដែលជាអ្នកពិនិត្យថា ពត៌មានដែលបានផ្តល់នេះ មានភាពគ្រប់គ្រាន់ ( ពិនិត្យមើលលើការពន្យល់ពីជំហានមួយទៅជំហាន មួយ អំពីផ្នែកសំខាន់ៗ នៃទំរង់ពត៌មាន គំរោង មិនបញ្ចូលផ្នែកបច្ចេកទេសលំអិត សុទ្ធសាធទេ)។

អ្នកគាំទ្របច្ចេកទេស ត្រូវបំពេញផ្នែកនៃទំរង់ដែលទាក់ទងពត៌មានបច្ចេកទេស ។
មេឃុំ ចៅសង្កាត់ ជាធម្មតាត្រូវបំពេញផ្នែកដែលមិនទាក់ទងនឹងបច្ចេកទេសដោយខ្លួនគាត់ផ្ទាល់ ឬក៏ ប្រគល់ភារកិច្ច ទៅជំទប់ ឬចៅសង្កាត់រងទី១ ទី២ ឬស្មៀនរបស់គាត់ ។

**ខាងក្រោមនេះជាគំរូហត្ថលេខា!!**

ចុះហត្ថលេខា

| ប្រធានឃុំ /សង្កាត់ | អ្នកជំនួយការបច្ចេកទេស | P / MOLA |
|---|---|---|
| ឈ្មោះ | ឈ្មោះ | ឈ្មោះ |
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| ថ្ងៃខែ ឆ្នាំ | ថ្ងៃ ខែ ឆ្នាំ | ថ្ងៃ ខែ ឆ្នាំ |
~~~~~~~~~~~~

## ៤.២. ពត៌មានដែលត្រូវបំពេញក្នុងទំរង់បែបបទ

| ពត៌មាន | ប្រភពពត៌មាន |
|---|---|
| ឈ្មោះគំរោង | ពត៌មានបានមកពីផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ |
| កាលបរិច្ឆេទបញ្ចប់ការសិក្សា | កាលបរិច្ឆេទដែលមន្ត្រីជំនួយការបច្ចេកទេសបញ្ចប់ការសិក្សាលើការដ្ឋានគំរោង |
| ឈ្មោះអ្នកគាំទ្របច្ចេកទេស | |
| អ្នកណាជាជំនួយការបច្ចេកទេស | "មន្ត្រីគាំទ្របច្ចេកទេស" "មន្ត្រីពីមន្ទីរជំនាញ" "ទីប្រឹក្សាឯកជន" ។ល។ |
| ទិសដៅនៃគំរោង | ត្រង់នេះគួរតែជាទិសដៅដែលបានសរសេរក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។ ទិសដៅនេះមិនគួរបង្កើតថ្មី ពេលដែលបំពេញទំរង់បែបបទនេះឡើយ ។ |
| វិស័យ | នេះជាវិស័យដែលមាននៅក្នុងផែនការអភិវឌ្ឍន៍ឃុំ (ការធ្វើផែនការត្រូវបាន ចែកចេញជា ៥ វិស័យ) ។ |
| ប្រភេទ | គឺជាប្រភេទគំរោងដូចមាននៅក្នុងបញ្ជី វិស័យ ប្រភេទគំរោង និងមន្ទីរពាក់ពន្ធ័ដែលទទួលខុសត្រូវ និងឧទាហរណ៍ខាងក្រោម ។ |
| លទ្ធផលគ្រោងទុក (ចេញពីផែនការអភិវឌ្ឍន៍ឃុំ សង្កាត់) | ផ្នែកនេះគួរតែចម្លងទាំងស្រុងពីផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ |
| លទ្ធផលស្នើឡើងក្រោយពីធ្វើការសិក្សា | ការសិក្សានេះអាចចេញជាលទ្ធផលក្នុងការផ្លាស់ប្តូរលទ្ធផលដែលបានស្នើឡើង ។ ឧទាហរណ៍ ក្នុងផែនការអភិវឌ្ឍន៍ឃុំ កំណត់ថា ស្ពានមួយ ប៉ុន្តែបន្ទាប់ពី បានធ្វើការសិក្សារួច គំរោងនោះបានក្លាយ ជាលូពីរទៅវិញ ។ បើពុំមានការផ្លាស់ប្តូរទេ ត្រូវសរសេរថា "ពុំមានការផ្លាស់ប្តូរទេ" ។ |
| ការប៉ាន់ស្មានតំលៃក្នុងផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ | នេះគឺជាការប៉ាន់ស្មានតំលៃគំរោង ដូចបានបង្ហាញក្នុងផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ |
| តំលៃប៉ាន់ស្មានក្រោយការសិក្សាគំរោង | នេះគឺជាការប៉ាន់ស្មានតំលៃគំរោង ក្រោយពីមន្ត្រីជំនួយការបច្ចេកទេសបានធ្វើគំនូរប្លង់ និងប៉ាន់ស្មានតំលៃរួច ។ |
| ឆ្នាំស្នើសុំការអនុវត្តន៍ | ក្នុងផែនការអភិវឌ្ឍន៍ឃុំបានបង្ហាញយ៉ាងច្បាស់ថា នៅឆ្នាំណាខ្លះដែលក្រុមប្រឹក្សាសំរេចវិភាជន៍មូលនិធិដើម្បីអនុវត្តគំរោង ។ គំរោងមួយអាចអនុវត្តលើសពីរយៈពេលមួយឆ្នាំ ឧ. ២០០៣ និង ២០០៤។ |
| អ្នកទទួលផលពីគំរោង | អ្នកទទួលផលផ្ទាល់ពីគំរោង គឺប្រជាជននៅមូលដ្ឋាន ដែលជាការពិតត្រូវប្រើប្រាស់លទ្ធផលនៃគំរោង ។ ចំនួនប្រជាជនទទួលផល គួរត្រូវបាន |

| ពត៌មាន | ប្រភពពត៌មាន |
|---|---|
| | ធ្វើការចុះបញ្ជីតាមភូមិនីមួយៗ ដោយមានបញ្ជាក់ច្បាស់លាស់នូវចំនួនស្ត្រី និងចំនួនគ្រួសារ ។ |
| ផែនទីគំរោង | ផែនទីនេះគួរត្រូវបានគូរ ដោយចំលងពីផែនទីឃុំដែលមានក្នុងផែនការអភិវឌ្ឍន៍ឃុំ ។ ប្រភេទ និងទីតាំងនៃលទ្ធផលគំរោង គួរបង្ហាញដោយប្រើប្រាស់និមិត្ត ឬសញ្ញាសាមញ្ញៗ ។ |
| ពត៌មានបច្ចេកទេសនិងប្លង់ការដ្ឋាន | ប្រភេទពត៌មានបច្ចេកទេស គឺពឹងផ្អែកទៅលើប្រភេទនៃគំរោង ។ មន្ត្រីគាំទ្របច្ចេកទេស ត្រូវតែទទួលខុសត្រូវក្នុងការផ្តល់ពត៌មាននេះ ដែលនឹងត្រូវ យកទៅបញ្ចូល ក្នុងទំរង់ពត៌មានគំរោង ។ |
| **ផ្នែកទី៤ : ធនធានមូលដ្ឋាន និងបរិស្ថាន** | |
| ៤.១. តើមានធនធានមូលដ្ឋានណា ដែលអាចត្រូវបានគេប្រើក្នុងការ សាងសង់គំរោងដែរឬទេ? | ឧទាហរណ៍ ដូចជាធនធានធម្មជាតិនៅមូលដ្ឋានរួមមាន : គ្រួសក្រហម ថ្មសំរាប់ សំណង់ ឬស្សី ឈើ ខ្សាច់ ។ល។ ជួនកាលមានធនធាន ដែលមនុស្សអាចធ្វើបាន ក៏អាចមានសារៈសំខាន់ផងដែរ ឧទាហរណ៍ដូចជាមានសិប្បម្មករផលិតឥដ្ឋ ដែលនៅជិតការដ្ឋានគំរោងសំណង់សាលារៀនជាដើម ។ |
| ៤.២. តើការសាងសង់គំរោងនេះ បណ្តាលឱ្យមានការខូចខាតឬប៉ះពាល់ ដល់កន្លែងមួយចំនួន ដែលមានសារៈ សំខាន់លើផ្នែកបរិស្ថាន ឬវប្បធម៌ ផ្សេងៗដែរឬទេ? | ឧទាហរណ៍ ព្រៃឈើ សួនសត្វ ឬប្រាង្គប្រាសាទ ទួលអ្នកតា ។ល។ |
| ៤.៣. តើការសាងសង់គំរោង បណ្តាលឱ្យមានការខូចខាត ឬប៉ះពាល់ ដល់ប្រភពផ្គត់ផ្គង់ទឹកដែលប្រជាជនកំពុងប្រើប្រាស់ដែរឬទេ? | ឧទាហរណ៍ : គំរោងផ្លូវដែលស្ថិតនៅជិតអូរ ឬប្រឡាយ ដែលប្រជាជន យក ទឹកនោះសំរាប់ការប្រើប្រាស់ក្នុងផ្ទះសំបែងរាល់ថ្ងៃ។ ប្រសិនបើ ផ្លូវត្រូវបានធ្វើការសាងសង់ ក្នុងរដូវវស្សា ទឹកកខ្វក់នឹងហូរ ពីផ្លូវចូលទៅក្នុង អូរ ឬប្រឡាយនោះ ជាហេតុបណ្តាលអោយប្រជាពលរដ្ឋមិនអាចប្រើប្រាស់ទឹកនោះបានឡើយ |
| ៤.៤. តើលទ្ធផលគំរោងជាផ្លូវថ្មីឬ? | ចំពោះផ្លូវថ្មីទាំងស្រុង (ផ្លូវដែលមិនមានចាស់ពីមុនមក) គួរមានការសិក្សា ពី ការវាយតំលៃផលប៉ះពាល់បរិស្ថាន ។ |
| ៤.៥ តើលទ្ធផលនៃគំរោង ជាប្រព័ន្ធធារាសាស្ត្រថ្មីមួយឬ? | ចំពោះគ្រោងការណ៍ធារាសាស្ត្រថ្មីមួយទាំងស្រុង គួរមានការសិក្សា ពីការវាយតំលៃផលប៉ះពាល់បរិស្ថាន ។ |
| **៥.កម្មសិទ្ធិដីធ្លី** | មេឃុំចៅសង្កាត់គួរផ្តល់ចំលើយ ដោយស្មោះត្រង់ចំពោះបញ្ហានេះ ។ វាមិនសំខាន់ទេ ថាតើអ្នកនោះមានប័ណ្ណកម្មសិទ្ធ ឬអត់ ។ |

| ពត៌មាន | ប្រភពពត៌មាន |
| --- | --- |
| | ម្ចាស់កម្មសិទ្ធិដី គឺជាអ្នកដែលប្រើប្រាស់ដី សំរាប់ធ្វើ កសិកម្មជាលក្ខណៈឯកជន ឬក្នុងគោលបំណងផ្សេងទៀត។ |
| ១. នៅលើដីរដ្ឋ ដែលមិនត្រូវបានគេ ប្រើប្រាស់សំរាប់ការធ្វើកសិកម្ម | ឧទាហរណ៍ : ការសាងសង់អាគារសិក្សាថ្មីមួយខ្នង នៅលើ បរិវេណសាលារៀន ដែលមានស្រាប់ ។ |
| ២. ដីឯកជនខ្លះនឹងត្រូវបានប្រើប្រាស់ ។ ពុំមានម្ចាស់ដីណានឹងត្រូវផ្តល់លើសពី ៥% នៃដីដែលខ្លួនមានសំរាប់គំរោងឡើយ ។ ពុំមានអាគារឯកជន ឬទីកន្លែងពាណិជ្ជកម្ម-អាជីវកម្មណាមួយត្រូវផ្លាស់ប្តូរ ឬបំផ្លាញឡើយ។ | ឧ : គំរោងពង្រីកផ្លូវដែលមានស្រាប់ មេឃុំ ចៅសង្កាត់ គួររៀបចំឱ្យមានការប្រជុំជាសាធារណៈ ហើយធ្វើការពន្យល់អំពីគំរោង ដល់ប្រជាពលរដ្ឋ ។ ម្ចាស់កម្មសិទ្ធិដីក៏ត្រូវយល់ដែរថា ពួកគេមិនត្រូវតែប្រគល់ដីរបស់ខ្លួនសំរាប់គំរោងឡើយ។ មេឃុំ ចៅសង្កាត់ និងម្ចាស់ដី ត្រូវឯកភាពគ្នាថា ប្រជាជនដែលបាត់បង់ដី មិនចាំបាច់ធ្វើការចូលរួមបដិភាគផ្សេងៗឡើយ។មេឃុំ ចៅសង្កាត់ ត្រូវធ្វើកំណត់ហេតុខ្លីមួយ អំពីការប្រជុំនេះ ហើយភ្ជាប់ទៅជាមួយនូវផែនទីដែលបង្ហាញពីដី ដែលត្រូវប្រើប្រាស់ និងហត្ថលេខាម្ចាស់ដី ដែលបានព្រមព្រៀងបរិច្ចាគដីរបស់ខ្លួន ។ |
| ៣.ម្ចាស់ដីខ្លះត្រូវផ្តល់ច្រើនជាង ៥% នៃដីដែលខ្លួនមាន ឬអាគារឯកជន ឬ ទីកន្លែងពាណិជ្ជកម្ម អាជីវកម្មខ្លះ ធ្វើការផ្លាស់ប្តូរទីកន្លែង ឬត្រូវបំផ្លាញចោល។ | ក្នុងករណីនេះ គួររៀបចំឱ្យមានរបាយការណ៍ពីការផ្ទេរកម្មសិទ្ធិដីធ្លី ពិសេសមួយ ដែលបំពេញដោយមន្ត្រីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ។ ការធ្វើដូច្នេះដើម្បីធ្វើឱ្យប្រាកដថា គ្មានម្ចាស់ដីណាម្នាក់ត្រូវបានគេប្រព្រឹត្តិដោយអយុត្តិធម៌ឡើយ ។ |
| **៦. ការសង្ខេបពត៌មាន** | |
| ៦.១. តើមានហេតុផលណា ដែល បណ្តាលឱ្យគំរោងនេះ មិនទទួលបានជោគជ័យដែរឬទេ? សំនួរនេះឆ្លើយ ដោយអ្នកគាំទ្របច្ចេកទេស | តាមជាក់ស្តែង មន្ត្រីជំនួយការបច្ចេកទេសរំពឹងថា គំរោងនឹងទទួលបានជោគជ័យ (ព្រោះគាត់បានរៀបចំគំនូរប្លង់) តែទោះជាយ៉ាងណាក៏ដោយ គាត់ប្រហែលជា ចង់ប្រើប្រអប់នេះ ដើម្បីកត់ត្រាចំណុចសំខាន់ៗមួយចំនួន ឧទាហរណ៍ គំរោងអាច ទទួលបានជោគជ័យយ៉ាងធំ តែក្នុងករណីគណៈកម្មាធិការកសិករប្រើប្រាស់ទឹកពូកែ និងថែទាំលទ្ធផលគំរោងបានល្អ ។ |
| ត្រួតពិនិត្យដោយមន្ត្រីអង្គភាពរដ្ឋបាលមូលដ្ឋាន | មន្ត្រីអង្គភាពរដ្ឋបាលមូលដ្ឋាន ប្រហែលជាមាន យោបល់ខ្លះ មុនពេលផ្ញើគំរោង ទៅមន្ទីរជំនាញ ដើម្បីពិនិត្យ បញ្ជាក់បច្ចេកទេស ។ |
| ៦.២ តើពត៌មានពីការសិក្សាគំរោង ទាំងអស់ត្រូវបានផ្តល់អោយគ្រប់គ្រាន់ហើយឬនៅ? | នេះគ្រាន់តែជាបញ្ជីដើម្បីពិនិត្យមើលថាពត៌មានទាំងអស់មានសព្វគ្រប់ ។ មន្ត្រី គាំទ្របច្ចេកទេសគួរគូស នៅក្នុង |

| ពត៌មាន | ប្រភពពត៌មាន |
|---|---|
| | ប្រអប់នីមួយៗ ដើម្បីបញ្ជាក់ថាពត៌មានទាំងអស់ បាន បំពេញក្នុងទំរង់បែបបទ ឬឯកសារភ្ជាប់ ។ មន្រ្តីអង្គភាព រដ្ឋបាលមូលដ្ឋាននឹង ពិនិត្យមើលបញ្ជីនោះដោយគូសក្នុង ប្រអប់បន្ទាប់ មុនពេលផ្ញើទៅមន្ទីរជំនាញ ដើម្បីបញ្ជាក់ បច្ចេកទេស ។ |
| ការចុះហត្ថលេខា | មេឃុំ ចៅសង្កាត់ និងមន្រ្តីជំនួយការបច្ចេកទេស ត្រូវចុះ ហត្ថលេខា ដើម្បីបញ្ជាក់ថារាល់ពត៌មានទាំងអស់បាន បំពេញគ្រប់គ្រាន់ និងត្រឹមត្រូវ ។ មន្រ្តីអង្គភាពរដ្ឋបាលមូលដ្ឋានចុះហត្ថលេខាដើម្បីបញ្ជាក់ថាបានឃើញ និងបានពិនិត្យរាល់ពត៌មានចប់សព្វគ្រប់ ។ |
| គំនូសប្លង់បច្ចេកទេស | រាល់គំនូសប្លង់បច្ចេកទេសណាមួយដែលនឹងត្រូវប្រើប្រាស់ សំរាប់គំរោង គួរភ្ជាប់មកជាមួយ ។ |

# បញ្ជីវិស័យ ប្រភេទគំរោង និងមន្ទីរពាក់ព័ន្ធ

| ល.រ | វិស័យ | ប្រភេទ | មន្ទីរពាក់ពន្ធ័ |
|---|---|---|---|
| 1 | សង្គមកិច្ច | ផ្គត់ផ្គង់ទឹកស្អាតជនបទ | មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ក្រុង |
| 2 | សង្គមកិច្ច | ផ្គត់ផ្គង់ទឹកស្អាតទីក្រុង | |
| 3 | សង្គមកិច្ច | អនាម័យនៅមូលដ្ឋាន | មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ក្រុង |
| 4 | សេដ្ឋកិច្ច | គមនាគមន៍ក្នុងតំបន់ជនបទ | មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ក្រុង |
| 5 | សេដ្ឋកិច្ច | គមនាគមន៍ក្នុងតំបន់ទីក្រុង | មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង |
| 6 | សង្គមកិច្ច | អប់រំ | មន្ទីរអប់រំខេត្ត ក្រុង |
| 7 | សង្គមកិច្ច | អប់រំមនុស្សពេញវ័យ | មន្ទីរអប់រំខេត្ត ក្រុង |
